**សេចក្តីប្រកាសព័ត៌មាន**

**ចេញផ្សាយជាបន្ទាន់**

**កាលបរិច្ឆេទ**

**ការចុះឈ្មោះបោះឆ្នោត ដោយចូលទៅតាមគេហទំព័រ (online) មានបកប្រែចេញជា ១០ភាសា**

ចិន ហិណ្ឌី ជប៉ុន ខ្មែរ កូរ៉េ ហ្វីលីពីន ថៃ វៀតណាម ជាភាសាដែលបានបន្ថែមចូលទៅក្នុង ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័ររបស់រដ្ឋ៕

**សាក្រាមិនតូ** – ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័ររបស់រដ្ឋកាលីហ្វ័រនីញ៉ា – បានចាប់ផ្តើមឡើងជាភាសា អង់គ្លេស និង ស្ពេននីស ក្នុងឆ្នាំ២០១២ – នៅពេលឥឡូវនេះ បានបូកបញ្ចូលប្រាំបីភាសាថែមទៀតៈ ចិន ហិណ្ឌី ជប៉ុន ខ្មែរ កូរ៉េ ហ្វីលីពីន ថៃ និងវៀតណាម។ បុគ្គលនិមួយៗអាចចុះឈ្មោះបោះឆ្នោត ដោយចូលទៅតាមគេហទំព័រ [http://registertovote.ca.gov](http://registertovote.ca.gov) ដើម្បីបំពេញព័ត៌មានទៅលើសំណុំបែបបទ ដែលជាភាសារបស់ខ្លួន៕

ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័រ ផ្តល់មកភាពស្រួលងាយដល់លោកអ្នក ដោយមិនបាច់ទៅ DMV យកសំណុំបែបបទមកបំពេញ រួចយកទៅទម្លាក់ក្នុងប្រអប់សំបុត្រទៀតនោះឡើយ។ ក្នុងការបោះឆ្នោតមុនខែវិច្ឆិកា ២០១២ មានបណ្តាជនច្រើនជាងកន្លះលាននាក់ បានចុះឈ្មោះបោះឆ្នោតជាលើកដំបូង ដោយប្រើប្រាស់គេហទំព័រនេះ៕

អ្នកតស៊ូមតិជាច្រើនសង្ឃឹមថា ការអោយមានភាសាជាច្រើននេះ នឹងបង្កើនចំនួនប្រជាជនមកចុះឈ្មោះបោះឆ្នោតជាលើកដំបូងអោយបានកាន់តែច្រើនឡើង ចំណោមប្រជាជនអាស៊ី–អាមេរិក និងប្រជាជនឡាទីនណូ នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ដែលពីមុនមកពួកគេមានចំនួនតិចក្នុងពេលបោះឆ្នោតម្តងៗ។ ប្រជាជនអាស៊ី–អាមេរិកចំនួន៥៨% និងប្រជាជនឡាទីនណូចំនួន៥៧% ប៉ុណ្ណោះដែលបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១២ ប្រៀបធៀបទៅនឹងប្រជាជនស្បែកសដែលមិនមែនឡាទីនណូចំនួន៧២% និងប្រជាជនអាហ្វ្រិក–អាមេរិកចំនួន៦៩%៕

ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័រ បានរៀបចំអោយមានភាពប្រសើរឡើងហើយងាយស្រួល ក្នុងការចូលទៅក្នុងគេហទំព័រដោយប្រើទូរស័ព្ទដៃទំនើប និងថាប្លិតដៃ (tablet)៕

ប្រជាពលរដ្ឋកាលីហ្វ័រនីញ៉ាត្រូវចុះឈ្មោះអោយបានទាន់ថ្ងៃច័ន្ទទី២០ ខែតុលា បើសិនជាមានបំណងនឹងបោះឆ្នោតក្នុងថ្ងៃទី៤ ខែវិច្ឆិកាខាងមុខនេះ។ សម្រាប់បុគ្គលដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចមកហើយ មិនចាំបាច់ចុះឈ្មោះម្តងទៀតនោះទេ លើកលែងតែចង់ប្តូរលំនៅដ្ឋាន ឬចង់ប្តូរគណបក្សគាំទ្រប៉ុណ្ណោះ៕

**<u>ប្រធានបទសម្រាប់អង្គការសហគមន៍ប្រើនូវពេលប្រកាសព័ត៌មាន</u>**

- “យើងស្នើសុំអោយគ្រប់ៗគ្នាក្នុងសហគមន៍ រួមជាមួយប្រព័ន្ធផ្សព្វផ្សាយ អាជីវកម្ម ស្ថាប័នជំនឿសាសនា និងសមាគមវប្បធម៌ ចូលរួមផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័រនេះផង។ ក្នុងគេហទំព័ររបស់ពួកយើងអាចភ្ជាប់លោកអ្នកទៅនឹងគេហទំព័ររបស់ការបោះឆ្នោតផងដែរ ហើយយើងសង្ឃឹមថា ក្រុមឯទៀតៗនឹងភ្ជាប់គេហទំព័រដូចជាយើងខ្ញុំដែរ៕”
- “មានប្រជាពលរដ្ឋកាលីហ្វ័រនីញ៉ាជាង៦លាននាក់ ដែលពួកគេមានសិទ្ធិនឹងបោះឆ្នោតតែមិនទាន់បានចុះឈ្មោះនូវឡើយ ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័រ នឹងអាចទាក់ទាញចិត្តពួកគេអោយមកចុះឈ្មោះ ក៏ប៉ុន្តែ គំរោងនេះអាចសម្រេចបាន លុះត្រាណាមានការជួយគាំទ្រផ្សព្វផ្សាយពីបណ្តាជនគ្រប់ៗ រូប៕”

- “__________ភាគរយក្នុងចំណោម___________នាក់ មានការពិបាកជាខ្លាំងដោយសារតែមិនចេះភាសាអង់គ្លេស។ ដូច្នេះហើយ ការចុះឈ្មោះបោះឆ្នោតចូលទៅតាមគេហទំព័រជាភាសាផ្ទាល់ខ្លួនអាចជាដំណោះស្រាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍និមួយៗបាន៕”

**<u>ទិន្នន័យសម្រាប់អង្គការសហគមន៍ប្រើ</u>**

ប្រជាពលរដ្ឋដែលមានចំណេះដឹងភាសាអង់គ្លេសតិចតួច មានចំនួនដូចខាងក្រោម (ទូរលេខអំពីប្រជាជនក្នុងរដ្ឋដែលមានអាយុ៥ឆ្នាំឡើងទៅ)

ខ្មែរអាមេរិកាំង ៤៤%

ចិនអាមេរិកាំង (មិនបូកបញ្ចូលចិនតៃវ៉ាន់នោះទេ) ៤៣%

ហ្វីលីពីនអាមេរិកាំង ១៩%

ឥណ្ឌាអាមេរិកាំង ២៣%

ជប៉ុនអាមេរិកាំង ១៨%

កូរ៉េអាមេរិកាំង ៤៨%

ឡាទីនណូ ៣៨%

តៃវ៉ាន់អាមេរិកាំង ៤៧%

ថៃអាមេរិកាំង ៤១%

វៀតណាមអាមេរិកាំង ៥២%